# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

LAND
JS LAND PLC

**ក្រុមហ៊ុន ជេអេស លែន ភីអិលស៊ី**
លេខ: ២០២៣/០១៥/ជមក ជ.អ.ល.

# សេចក្តីជូនដំណឹង
## ស្តីពី
## ការទទួលបានពានរង្វាន់សម្រាប់ការអភិវឌ្ឍន៍ខុនដូដែលមានតម្លៃសមរម្យបំផុត របស់ក្រុមហ៊ុន ជេអេស លែន ភីអិលស៊ី

**ក្រុមហ៊ុន ជេអេស លែន ភីអិលស៊ី (ជ.អ.ល.)** ជាក្រុមហ៊ុនអភិវឌ្ឍន៍អចលនទ្រព្យដំបូងគេក្នុងព្រះរាជាណាចក្រកម្ពុជា ដែលបានចុះបញ្ជីភាគហ៊ុនរបស់ខ្លួនជាមួយផ្សារមូលបត្រកម្ពុជា **"ផមក"** មានមោទនភាពសូមជម្រាបជូនវិនិយោគិន និងសាធារណជនទាំងឡាយមេត្តាជ្រាបថាក្រុមហ៊ុនរបស់យើងខ្ញុំបានទទួលពានរង្វាន់ **"ការអភិវឌ្ឍន៍ខុនដូដែលមានតម្លៃសមរម្យបំផុត"** នៅក្នុងកម្មវិធីដ៏ល្បីល្បាញមួយឈ្មោះថា PropertyGuru Cambodia Property Awards ។

ព្រឹត្តិការណ៍នេះបានប្រព្រឹត្តឡើងនៅថ្ងៃសុក្រ ១០ រោច ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២៣ ក្នុងកម្មវិធី PropertyGuru Cambodia Property Awards នៅទីក្រុងភ្នំពេញ នៃព្រះរាជាណាចក្រកម្ពុជា ដែលនេះជាសមិទ្ធិផលឆ្នើមមួយកម្រិតបន្ថែមទៀត របស់ក្រុមហ៊ុន ជេអេស លែន ភីអិលស៊ី នៅក្នុងវិស័យអភិវឌ្ឍន៍ខុនដូជាមួយនឹងតម្លៃសមរម្យត្រូវបានការទទួលស្គាល់ និងការចូលរួមអបអរសាទរ។

PropertyGuru Cambodia Property Awards គឺត្រូវបានស្គាល់ថាជាកម្មវិធីពានរង្វាន់ ដ៏ល្បីល្បាញពោរពេញដោយភាពជឿជាក់ និងឧត្តមភាពក្នុងការទទួលស្គាល់សមិទ្ធិផលគួរឱ្យកត់សម្គាល់ក្នុងវិស័យអចលនទ្រព្យ ព្រមទាំងបានបង្ហាញពីការយកចិត្តទុកដាក់មកលើក្រុមហ៊ុន ជេអេស លែន ភីអិលស៊ី ដែលក្រុមហ៊ុនមានការផ្តល់នូវដំណោះស្រាយគេហដ្ឋានជូនចំពោះអតិថិជនជាមួយនឹងតម្លៃសមរម្យប្រកបដោយគុណភាពខ្ពស់នៅក្នុងទីក្រុងភ្នំពេញ។ ពានរង្វាន់នេះ គឺជាសក្ខីភាពបញ្ជាក់ពីការប្តេជ្ញាចិត្តរបស់ក្រុមហ៊ុនចំពោះការរចនា ច្នៃប្រឌិត និងការពេញចិត្តពីសំណាក់អតិថិជន។

ការទទួលស្គាល់នេះក៏បានពង្រឹងជំហររបស់ក្រុមហ៊ុន ជេអេស លែន ភីអិលស៊ី នៅក្នុងវិស័យអចលនទ្រព្យក្នុងនាមជាអ្នកអភិវឌ្ឍន៍ខុនដូដែលគួរឱ្យទុកចិត្តនៅក្នុងទីផ្សារកម្ពុជាផងដែរ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមវិនិយោគិន និងសាធារណជន មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃអង្គារ ៦ កើត ខែស្រាពណ៍ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣
**ក្រុមហ៊ុន ជេអេស លែន ភីអិលស៊ី**

ព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុន ជេអេស លែន ភីអិលស៊ី JS LAND PLC. KINGDOM OF CAMBODIA